ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តព្រៃវែង

លេខ ០១៤ ... [illegible] ១១

# សេចក្តីជូនដំណឹង

## ស្តីពីការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធ

- បានឃើញប្រកាសលេខ ០៧៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធ
- បានឃើញសារាចរលេខ ០០៩ សរណន.សហវ ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការអនុវត្តន៍វិធានការតឹងទារបំណុលពន្ធ។

អភិបាលនៃគណៈអភិបាលខេត្តសូមជូនដំណឹងថា៖

១- អ្នកជាប់ពន្ធ ត្រូវមានកាតព្វកិច្ចបង់ពន្ធទៅតាមកាលបរិច្ឆេទកំណត់នៃបទប្បញ្ញត្តិស្តីពីពន្ធដារ។

២- ចំពោះបុគ្គលដែលមិនបានបង់ពន្ធតាមកាលកំណត់ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ១០ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬ ចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។

៣- ប្រសិនបើបុគ្គលមិនបានបង់ពន្ធក្នុងរយៈ ១៥ ថ្ងៃ ក្រោយពេលបានទទួលលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ពន្ធបន្ថែមត្រូវកំណត់តាមអត្រា ២៥ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺត បូកនឹងការប្រាក់ ២ ភាគរយនៃទឹកប្រាក់ពន្ធបង់យឺតសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធនោះនៅមិនទាន់បានបង់។

៤- ករណីរឹងរូសមិនព្រមជំរះបំណុលពន្ធ គណៈកម្មការតឹងទារបំណុលពន្ធ ឬ អនុគណៈកម្មការតឹងទារបំណុលពន្ធថ្នាក់ស្រុកអនុវត្តវិធានការតឹងទារបំណុលពន្ធ ជារួមមានដូចតទៅ៖

   ក- ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល សំដៅដល់ការឃាត់ទុកទំនិញ ដែលជារបស់អ្នកជំពាក់បំណុលពន្ធ និងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីចាត់ការគយនិងរដ្ឋាករ និងការលក់ទំនិញទាំងនោះបើសិនជាមានការចាំបាច់ ក្នុងបរិមាណដែលមានតម្លៃមិនលើសពីចំនួនទឹកប្រាក់សំរាប់ ទូទាត់បំណុលពន្ធ ទោសទ័ណ្ឌ និងចំណាយក្នុងការប្រមូលពន្ធ

   ខ- ការឃាត់ទុកគណនីនៅធនាគាររបស់អ្នកជំពាក់បំណុលពន្ធ និងការតម្រូវឲ្យធនាគារប្រគល់ឲ្យនាយកដ្ឋានពន្ធដារនូវប្រាក់ក្នុងគណនីរបស់បុគ្គលនោះ ក្នុងចំនួនដែលមិនលើសពីចំនួនទឹកប្រាក់សំរាប់ទូទាត់បំណុលពន្ធ ទោសទ័ណ្ឌ និងចំណាយក្នុងការប្រមូលពន្ធ

   គ- ការចេញលិខិតជូនដំណឹងទៅកាន់អាជ្ញាធរមានសម្ថកិច្ចស្នើសុំឲ្យទុកជាមោឃៈនូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗដែលអនុញ្ញាតឲ្យអ្នកជំពាក់បំណុលពន្ធអនុវត្តសកម្មភាពណាមួយ

   ឃ- ការរឹបអូស ការលក់ទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ក្នុងចំនួនដែលមានតម្លៃគ្រប់គ្រាន់សម្រាប់ទូទាត់បំណុលពន្ធ ទោសទ័ណ្ឌ និងចំណាយក្នុងការប្រមូលពន្ធ ទោះបីជាទ្រព្យសម្បត្តិនោះត្រូវកាន់កាប់ដោយបុគ្គលខ្លួនឯង ឬដោយតតីយជនក្តី និងការតម្រូវឲ្យបុគ្គលនានាដែលមានកាតព្វកិច្ចត្រូវសងអ្វីមួយដល់អ្នកជំពាក់បំណុលពន្ធ ឲ្យប្រគល់សំណងនោះដល់នាយកដ្ឋានពន្ធដារទោះជាសាច់ប្រាក់ ឬ ជាវត្ថុក្តី ក្នុងចំនួនដែលមានតម្លៃមិនលើសពីចំនួនទឹកប្រាក់សំរាប់ទូទាត់បំណុលពន្ធ ទោសទ័ណ្ឌ និងចំណាយក្នុងការប្រមូលពន្ធ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា គ្រប់អ្នកជាប់ពន្ធដែលមានការពាក់ព័ន្ធបំណុលពន្ធនឹងយកចិត្តទុកដាក់ជំរះបំណុលពន្ធ នៅស្នាក់ការពន្ធដារស្រុកដែលអាជីវកម្មដ្ឋានស្ថិតនៅជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០១១

**អភិបាលនៃគណៈអភិបាលខេត្ត**

**អ៊ុំ_សារី**

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
- និងស្ថាប័នពាក់ព័ន្ធ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ